- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនលោក **ព្រាប ទុន្ធី** សមាជិកក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ ដែលបានលះបង់កំលាំងកាយចិត្ត និង បរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងសង្គមកិច្ច នៅ**វត្តស្វាយបូព្រឹក្ស** ស្ថិតនៅក្នុងឃុំជាខ្លាង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៩០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនចំនួន ០៧ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ និងសមិទ្ធផលនានា នៅ**វត្តប្រាសាទបីសិរីសោភ័ណ្ឌ** ស្ថិតនៅក្នុងឃុំចំណាលើ ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៥ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **ខ្វន សុភារម្យ** ព្រះចៅអធិការវត្តប្រាសាទបីសិរីសោភ័ណ្ឌ បច្ច័យចំនួន ១២.០០០ ដុល្លារ
២-លោក **អ៊ុង សៀវហ៊ុយ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១២.៥០០ ដុល្លារ
៣-លោក **ថុំ គឹមហ៊ុន** អភិបាលរងស្រុកស្ទោង ថវិកាចំនួន ១០.៥០០ ដុល្លារ
៤-លោកស្រី **មុំល ឡុន** អភិបាលរងស្រុកស្ទោង ថវិកាចំនួន ១០.៥០០ ដុល្លារ
៥-ឧបាសក **ហ៊ុំ ទូច** អាចារ្យវត្តប្រាសាទបីសិរីសោភ័ណ្ឌ ថវិកាចំនួន ១០.២០០ ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០២ គ្រឿង ផ្តល់ជូន :**

១- លោក **ខូត ដៅ** សប្បុរសជននៅខេត្តកំពង់ធំ ថវិកាចំនួន ៥.៥០០ ដុល្លារ
២-ឧបាសក **យ៉ាន់ យ៉េត** សប្បុរសជននៅខេត្តកំពង់ធំ ថវិកាចំនួន ៥.៥០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពង់ធំ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ផ្តល់ជូនមន្ត្រីរាជការ ចំនួន ០២រូប ដែលបានលះបង់កំលាំងកាយ ចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ និងសមិទ្ធផលនានា នៅ**វត្តប្រាសាទបីសិរីសោភ័ណ្ឌ** ស្ថិតនៅក្នុងឃុំចំណាលើ ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានរាយនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | **ព្រឹម វដ្ឋា** | ប្រធានក្រុមប្រឹក្សាស្រុកស្ទោង | ថវិកាចំនួន ១៥.០០០ ដុល្លារ |
| ២-លោក | **ហេង ស៊ីធីម** | អភិបាលស្រុកស្ទោង | ថវិកាចំនួន ១៥.០០០ ដុល្លារ |

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពង់ធំ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤០២ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតជាន់ខ្ពស់

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១- លោកវរសេនីយ៍ទោ **គឿន សុភក្ត្រា** អត្តលេខ ៦៤៣៦១
២- លោកវរសេនីយ៍ទោ **នូ ឌឿន** អត្តលេខ ០២១៨៧
៣- លោកវរសេនីយ៍ទោ **សំ ដារ៉ា** អត្តលេខ ០៧៨៨៨
៤- លោកវរសេនីយ៍ទោ **ចូ ឥដ្ឋិមា** អត្តលេខ ០៣១៣២
៥- លោកវរសេនីយ៍ទោ **សៀង សុខត្ថិ** អត្តលេខ ៥៤៨៦៦
៦- លោកវរសេនីយ៍ទោ **ទូន ធី** អត្តលេខ ០៨៤៧៨
៧- លោកវរសេនីយ៍ទោ **ទ្រី ភាព** អត្តលេខ ៦៤៤០៦
៨- លោកវរសេនីយ៍ទោ **ជា សុគន្ធា** អត្តលេខ ០៦៤៧៨ ៕

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះតាម ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤០៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សម្រេច**

**មាត្រា ១:** ផ្ទេរភារកិច្ចលោក **ឡាយ ម៉ារីទ៉ុ** បច្ចុប្បន្នអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ទៅជាអគ្គនាយករងនៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤០៤ .អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ៖**

ត្រូវបានបំពាក់មេដាយ **មាស** ស្ថាបនាជាតិ ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ និងសប្បុរសជនចំនួន ០៦ នាក់ មានចិត្តសប្បុរសជួយឧបត្ថម្ភជាថវិកា សំភារៈផ្ទាល់ខ្លួនដល់កងកំលាំងនគរបាលជាតិ និងជួយកសាងប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរៀង ប៉ុស្តិ៍នគរបាលរដ្ឋបាលថ្មី ប៉ុស្តិ៍នគរបាលរដ្ឋបាលចេក ប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយតឿ ប៉ុស្តិ៍នគរបាលរដ្ឋបាលបាទី ជួសជុលអគារស្នាក់នៅ និងចាក់សាបវរសេនាតូចលេខ៦០៩ និងវរសេនាតូចលេខ៦១១ នគរបាលការពារព្រំដែនគោក ខេត្តស្វាយរៀង ដែលមានទឹកប្រាក់សរុបចំនួន ៨៥.១៥៨ ដុល្លា (ប្រាំបីម៉ឺន ប្រាំពាន់ មួយរយហាសិបប្រាំបីដុល្លា) ដូចមានរាយនាមខាងក្រោម ៖

១- ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គលេខ ០០៦៦ អគ្គស្នងការនគរបាលជាតិ ចំណាយថវិកាអស់ចំនួន ២៤.៥០០ ដុល្លា (ពីរម៉ឺន បួនពាន់ ប្រាំរយដុល្លា)

២- លោកឧត្តមសេនីយ៍ឯក សុខ ផល អគ្គលេខ ០០៥១ អគ្គស្នងការរងនគរបាលជាតិ ចំណាយថវិកាអស់ចំនួន ១៤.១០៣ ដុល្លា (មួយម៉ឺន បួនពាន់ មួយរយបីដុល្លា)

៣- លោកឧកញ៉ា ខូវ គឹមបាក់ ប្រធានក្រុមហ៊ុនម៉េង្សរ៉ាមី អាស៊ី ចំណាយថវិកាអស់ចំនួន ១២.០០៥ ដុល្លា (មួយម៉ឺន ពីរពាន់ ប្រាំដុល្លា)

| | | |
|---|---|---|
| ៤- លោកឧកញ៉ា | លី ហួរ | ប្រធានក្រុមហ៊ុន លី ហួ ចំណាយថវិកាអស់ចំនួន ១០.១០៨ ដុល្លា (មួយម៉ឺន មួយរយ ប្រាំបីដុល្លា) |
| ៥- លោកវរសេនីយ៍ត្រី | ស៊ិន វាសនា អត្តលេខ ២១២២២ | មេបញ្ជាការវរលេខ៦០៩ ចំណាយថវិកាអស់ចំនួន ១១.៣៣៩ ដុល្លា (មួយម៉ឺន មួយពាន់ បីរយសាមសិបប្រាំបួនដុល្លា) |
| ៦- លោកវរសេនីយ៍ត្រី | គង់ សំអឿន អត្តលេខ ១៣០២២ | មេបញ្ជាការវរលេខ៦១១ ចំណាយថវិកាអស់ចំនួន ១៣.១០៣ ដុល្លា (មួយម៉ឺន បីពាន់ មួយរយបីដុល្លា) |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល ៖***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា១ និងមាត្រា២*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៧២ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ ៨៥៥-២៣-៧២៤ ៦៦៤
Phone 855-23-724 664 Fax 855-23-427 798
mef_admin@yahoo.com

- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ១៤០៥ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងកិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល
- បានឃើញសារាចរណែនាំលេខ ០១៣ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរដ្ឋទេយ្យចំណូល
- តាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាពេលបច្ចុប្បន្ន

## **សម្រេច**

**ប្រការ ១** : ត្រូវបានដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលមានទម្រង់ឯកភាព និងបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានគំរូជូនភ្ជាប់នឹងប្រកាសនេះ។

**ប្រការ ២** : បង្កាន់ដៃបង់ប្រាក់ ចែកចេញជាពីរប្រភេទ ៖

- បង្កាន់ដៃបង់ប្រាក់ប្រភេទ ១ មានគំរូលេខ ០១ សហវ/ចមព : ប្រើប្រាស់ជាទូទៅសម្រាប់ការប្រមូល ឬការទទួលចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលមានតម្លៃប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈនៃសេវាសាធារណៈរបស់រដ្ឋ។
- បង្កាន់ដៃបង់ប្រាក់ប្រភេទ ២ មានគំរូលេខ ០២ សហវ/ចមព : សម្រាប់ប្រើប្រាស់ផ្តោតលើការប្រមូល ឬការទទួលចំណូលមិនមែនសារពើពន្ធទាំងឡាយណាដែលមានតម្លៃសេវាដូចៗគ្នា ផ្តល់លទ្ធភាពដល់ការបោះពុម្ពតម្លៃស្រេចជាមុននៅលើបង្កាន់ដៃបង់ប្រាក់ និងគ្មានការចាំបាច់តម្រូវឱ្យសរសេរបំពេញព័ត៌មានអ្វីឡើយ។

**ប្រការ ៣** : បង្កាន់ដៃបង់ប្រាក់ប្រភេទ ១ ត្រូវបានបោះពុម្ពចងក្រងជាសៀវភៅ មានដាក់លេខកូដក្បាលសៀវភៅ និងលេខរៀងបង្កាន់ដៃ។ សៀវភៅបង្កាន់ដៃមួយក្បាលៗមានបង្កាន់ដៃបង់ប្រាក់សរុបចំនួន ៥០ (ហាសិប) និងបង្កាន់ដៃបង់ប្រាក់នីមួយៗបោះពុម្ពឡើងជា ៣(បី)ច្បាប់ត្រួតជាប់គ្នា ដែលត្រូវបានកំណត់ដូចខាងក្រោម ៖

- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី ១ មានពណ៌ស ជាច្បាប់ដើម សម្រាប់ទុកជាសក្ខីប័ត្រភ្ជាប់សំណុំរឿង
- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី ២ មានពណ៌ផ្ទៃមេឃ ជាច្បាប់ចម្លង សម្រាប់ប្រគល់ជូនអ្នកបង់ប្រាក់
- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី ៣ មានពណ៌ផ្កាឈូក ជាច្បាប់ចម្លង សម្រាប់រក្សាទុកនៅជាប់នឹងក្បាលសៀវភៅ។

**ប្រការ ៤** : បង្កាន់ដៃបង់ប្រាក់ប្រភេទ ២ ត្រូវបានបោះពុម្ពចងក្រងជាសៀវភៅ មានដាក់លេខកូដក្បាលសៀវភៅ និងលេខរៀងបង្កាន់ដៃ។ សៀវភៅបង្កាន់ដៃមួយក្បាលៗ មានបង្កាន់ដៃសរុបចំនួន ២០០(ពីររយ) និងបង្កាន់ដៃនីមួយៗបោះពុម្ពឡើងជា ៣(បី)ច្បាប់ស្ថិតនៅបន្តបន្ទាប់គ្នាលើសន្លឹកតែមួយ និងមានពណ៌ស្វាយដូចៗគ្នាទាំងអស់។ ការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រភេទ ២ ត្រូវបានកំណត់ដូចតទៅ ៖

- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកខាងចុង សម្រាប់ប្រគល់ជូនអ្នកបង់ប្រាក់
- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកកណ្តាល សម្រាប់ទុកជាសក្ខីប័ត្រភ្ជាប់សំណុំរឿង
- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកខាងគល់ សម្រាប់រក្សាទុកនៅជាប់នឹងក្បាលសៀវភៅ។

**ប្រការ ៥** : នាយកដ្ឋានចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់អំពីទម្រង់ លក្ខណបច្ចេកទេស និងបរិមាណនៃបង្កាន់ដៃបង់ប្រាក់ និងធ្វើកិច្ចសហការជាមួយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការបោះពុម្ពបង្កាន់ដៃបង់ប្រាក់ តាមនីតិវិធីហិរញ្ញវត្ថុ។

**ប្រការ ៦** : ការគ្រប់គ្រង និងការបើកផ្តល់បង្កាន់ដៃបង់ប្រាក់ ស្ថិតក្រោមការចាត់ចែងរបស់នាយកដ្ឋានចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៧** : រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល នៃក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរ និងអង្គភាព នៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលមានទម្រង់ឯកភាព និងបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការប្រមូលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ដើម្បីជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់ពីបានទទួលប្រាក់ចំណូល រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល ត្រូវចេញបង្កាន់ដៃបង់ប្រាក់មួយច្បាប់ប្រគល់ជូនទៅអតិថិជន។

**ប្រការ ៨** : សេចក្តីណែនាំលម្អិតលើការបោះពុម្ព ការបើកផ្តល់ ការប្រើប្រាស់ ការកត់ត្រាតាមដាន និងការធ្វើរបាយការណ៍ស្តីពីបង្កាន់ដៃបង់ប្រាក់ នឹងកំណត់ដោយសារាចរណែនាំមួយដោយឡែក។

**ប្រការ ៩** : ករណីប្រព្រឹត្តអំពើល្មើសទៅនឹងខ្លឹមសារប្រការ ៧ នៃប្រកាសនេះ រួមទាំងការអនុវត្តប្រមូលចំណូលដោយប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ក្លែងបន្លំ នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីផ្សេងទៀត។

**ប្រការ ១០** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១១** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ តទៅ។

**ប្រការ ១២** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតក្រោមឱវាទក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១១

គាត ឈន់

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល
- រដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត
- រតនាគាររាជធានី ខេត្ត
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...០០៥.......សហវ.....

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១១

# សារាចរណែនាំ
# ស្តីពី
# ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់

ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ស្របតាមក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដោយអនុលោមទៅតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ បទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីកិច្ចដំណើរការនៃបង្កាន់ដៃបង់ប្រាក់ ដូចតទៅ ៖

## ផ្នែកទី១
## បង្កាន់ដៃបង់ប្រាក់

### ១- និយមន័យ

បង្កាន់ដៃបង់ប្រាក់ គឺជាប្រភេទសក្ខីប័ត្រដែលបញ្ជាក់អំពីការបង់ និងការទទួលប្រាក់ចំណូលមិនមែនសារពើពន្ធដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ រវាងអតិថិជន និងរដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល សម្រាប់ជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

អំណឹះតទៅ នៅក្នុងសារាចរណែនាំនេះ ពាក្យថា រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល ត្រូវបានសន្មតហៅថា អ្នកប្រមូលចំណូល។

### ២- ទម្រង់ និងលក្ខណៈសម្គាល់

បង្កាន់ដៃបង់ប្រាក់មានពីរប្រភេទ ៖ គឺបង្កាន់ដៃបង់ប្រាក់ប្រភេទ១ និងបង្កាន់ដៃបង់ប្រាក់ប្រភេទ២។

#### ២.១- បង្កាន់ដៃបង់ប្រាក់ប្រភេទ ១

បង្កាន់ដៃបង់ប្រាក់ប្រភេទ១ មានទំហំ១០ សង់ទីម៉ែត្រ គុណនឹង១៧ សង់ទីម៉ែត្រ ត្រូវបានបោះពុម្ពចងក្រងជាសៀវភៅ មានដាក់លេខកូដក្បាលសៀវភៅ និងលេខរៀងបង្កាន់ដៃ។ សៀវភៅបង្កាន់ដៃមួយក្បាលៗ មានចំនួន ៥០ (ហាសិប)បង្កាន់ដៃ។ បង្កាន់ដៃនីមួយៗបោះពុម្ពឡើងជា ៣(បី)ច្បាប់ ត្រួតជាប់គ្នា ដែលត្រូវបានកំណត់ដូចតទៅ ៖

- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី១ មានផ្ទៃពណ៌ស ជាច្បាប់ដើម សម្រាប់ទុកជាសក្ខីប័ត្រភ្ជាប់សំណុំរឿង
- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី២ មានផ្ទៃពណ៌ផ្ទៃមេឃ ជាច្បាប់ចម្លង សម្រាប់ប្រគល់ជូនអតិថិជន
- បង្កាន់ដៃបង់ប្រាក់ច្បាប់ទី៣ មានផ្ទៃពណ៌ផ្កាឈូក ជាច្បាប់ចម្លង សម្រាប់រក្សាទុកនៅជាប់នឹងក្បាលសៀវភៅ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_admin@yahoo.com

- នៅផ្នែកខាងលើនៃក្បាលបង្កាន់ដៃនីមួយៗ ចំហៀងខាងឆ្វេងមានរូបសញ្ញាសម្គាល់ ឈ្មោះ និងអង្គភាពរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។
- នៅផ្នែកខាងលើនៃក្បាលបង្កាន់ដៃនីមួយៗ ចំហៀងខាងស្តាំមានលេខបង្កាន់ដៃ និងលេខកូដសម្ងាត់។
- នៅចំកណ្តាលនៃផ្ទៃបង្កាន់ដៃនីមួយៗ មានរំលេចរូបសញ្ញាសម្គាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២.២- បង្កាន់ដៃបង់ប្រាក់ប្រភេទ ២**

បង្កាន់ដៃបង់ប្រាក់ប្រភេទ២ មានទំហំ៩ សង់ទីម៉ែត្រ គុណនឹង៩ សង់ទីម៉ែត្រ ត្រូវបានបោះពុម្ពចងក្រងជាសៀវភៅ មានដាក់លេខកូដក្បាលសៀវភៅ និងលេខរៀងបង្កាន់ដៃ។ សៀវភៅបង្កាន់ដៃមួយក្បាលៗ មានចំនួន ២០០(ពីររយ) បង្កាន់ដៃ។ បង្កាន់ដៃនីមួយៗ ត្រូវបានបោះពុម្ពជា ៣(បី)ច្បាប់ ស្ថិតនៅបន្តបន្ទាប់គ្នាលើសន្លឹកតែមួយ និងមានផ្ទៃពណ៌ស្វាយដូចគ្នាទាំងអស់ ដែលត្រូវបានកំណត់ដូចខាងក្រោម ៖

- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកខាងចុង សម្រាប់ប្រគល់ជូនអតិថិជន
- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកកណ្តាល សម្រាប់ទុកជាសក្ខីប័ត្រភ្ជាប់សំណុំរឿង
- បង្កាន់ដៃបង់ប្រាក់ដែលស្ថិតនៅផ្នែកខាងគល់ សម្រាប់រក្សាទុកនៅជាប់នឹងក្បាលសៀវភៅ។

- បង្កាន់ដៃបង់ប្រាក់ប្រភេទ២ ជាប្រភេទបង្កាន់ដៃបង់ប្រាក់ដែលមានលក្ខណៈបំព្រួញនៃបង្កាន់ដៃបង់ប្រាក់ប្រភេទ១ ដែលបង្កើតឡើងដើម្បីជួយសម្រួលការងារប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យមានភាពងាយស្រួល និងឆាប់រហ័ស។ នៅលើបង្កាន់ដៃបង់ប្រាក់ប្រភេទ២ នេះ មានបោះពុម្ពជាស្រេចទាំងអត្ថន័យសេវា ទាំងចំនួនទឹកប្រាក់ដែលត្រូវប្រមូលចំណូល។
- នៅផ្នែកខាងលើនៃក្បាលបង្កាន់ដៃនីមួយៗ ចំហៀងខាងឆ្វេងមានរូបសញ្ញាសម្គាល់ ឈ្មោះ និងអង្គភាពរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។
- នៅផ្នែកខាងលើនៃក្បាលបង្កាន់ដៃនីមួយៗ ចំហៀងខាងស្តាំមានលេខបង្កាន់ដៃ និងលេខកូដសម្ងាត់។
- នៅចំកណ្តាលនៃផ្ទៃបង្កាន់ដៃនីមួយៗ មានរំលេចរូបសញ្ញាសម្គាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៣- មុខសញ្ញាប្រើប្រាស់

បង្កាន់ដៃបង់ប្រាក់ប្រភេទ១ សម្រាប់ប្រើប្រាស់ជាទូទៅក្នុងការប្រមូល ឬការទទួលចំណូលមិនមែនសារពើពន្ធ។ បង្កាន់ដៃនេះ ប្រើសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធទាំងឡាយណា ដែលសំណូមពរចាំបាច់នៃការងារពាក់ព័ន្ធតម្រូវឱ្យអ្នកប្រមូលចំណូលសរសេរបំពេញឈ្មោះ និងអង្គភាពរបស់អតិថិជន (ករណីចាំបាច់) អត្ថន័យប្រភេទសេវា ចំនួនទឹកប្រាក់ដែលត្រូវបង់ ចុះកាលបរិច្ឆេទ និងមានចុះហត្ថលេខារបស់អ្នកប្រមូលចំណូល។

បង្កាន់ដៃបង់ប្រាក់ប្រភេទ២ ប្រើសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធទាំងឡាយណាដែលសំណូមពរនៃការងារពាក់ព័ន្ធគ្មានតម្រូវការចាំបាច់នូវព័ត៌មានស្តីពីឈ្មោះ និងអង្គភាពរបស់អតិថិជនឡើយ។ នៅពេលប្រើប្រាស់ក្នុងការប្រមូលចំណូល គ្រាន់តែតម្រូវឱ្យអ្នកប្រមូលចំណូលចុះកាលបរិច្ឆេទ និងចុះហត្ថលេខា នៅលើសន្លឹកនៃបង្កាន់ដៃនោះ ចំថ្ងៃដែលធ្វើកិច្ចប្រតិបត្តិការប្រមូលចំណូលតែប៉ុណ្ណោះ។

ការចុះកាលបរិច្ឆេទនៅលើសន្លឹកនៃបង្កាន់ដៃបង់ប្រាក់ អ្នកប្រមូលចំណូលអាចសរសេរបំពេញដោយដៃ ឬប្រថាប់ត្រាកាលបរិច្ឆេទក៏បាន។

## ៤- លក្ខខណ្ឌប្រើប្រាស់

មានតែអ្នកប្រមូលចំណូល ជាអ្នកអនុវត្តន៍ហែកបង្កាន់ដៃបង់ប្រាក់ទាំងពីរប្រភេទជូនអតិថិជន ជាថ្នូរនឹងការទទួលប្រាក់ ឬមូលប្បទានប័ត្រ។ ការបង្កើតរដ្ឋទេយ្យចំណូល និងការតែងតាំងរដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល ត្រូវអនុវត្តតាមនីតិវិធី និងតាមគំរូណែនាំ ដែលមានជាធរមាន។ ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើប្រកាសអន្តរក្រសួងស្តីពីការបង្កើតរដ្ឋទេយ្យចំណូល និងការតែងតាំងរដ្ឋទេយ្យករ

ចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល ចំនួនមួយច្បាប់ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ដើម្បីតម្កល់ទុកជាឯកសារ។ មន្ទីរជំនាញរាជធានី ខេត្ត និងគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្ញើដីកាស្តីពីការបង្កើតរដ្ឋទេយ្យចំណូល និងការតែងតាំងរដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល ចំនួនមួយច្បាប់ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីតម្កល់ទុកជាឯកសារ។

អ្នកប្រមូលចំណូលត្រូវសរសេរបំពេញឱ្យបានត្រឹមត្រូវ និងពេញលេញ នៅក្នុងបង្កាន់ដៃបង់ប្រាក់។ ក្នុងករណីមានការសរសេរខុស អ្នកប្រមូលចំណូលត្រូវគូសសញ្ញាខ្វែង និងចុះហត្ថលេខាសង្ខេបនៅលើបង្កាន់ដៃបង់ប្រាក់ច្បាប់ដើមដែលសរសេរខុសនោះដើម្បីទុកជាការបញ្ជាក់ ហើយត្រូវរក្សាទុកទាំងច្បាប់ដើម ទាំងច្បាប់ចម្លងឱ្យនៅជាប់នឹងក្បាលសៀវភៅ។ បន្ទាប់មកត្រូវបន្តប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ថ្មី ដែលមានលេខរៀងបន្ទាប់។

សៀវភៅបង្កាន់ដៃបង់ប្រាក់(ទាំងពីរប្រភេទ)នីមួយៗ ត្រូវបានកំណត់ឱ្យប្រើប្រាស់ប្រចាំឆ្នាំ។ សៀវភៅបង្កាន់ដៃបង់ប្រាក់ណាមួយដែលបានប្រើប្រាស់នៅឆ្នាំមុនហើយ មិនអនុញ្ញាតឱ្យប្រើប្រាស់បន្តសម្រាប់ការប្រមូលចំណូលនៅក្នុងឆ្នាំក្រោយទៀតទេ។ ទោះបីជាសៀវភៅបង្កាន់ដៃក្បាលនោះ នៅមានសេសសល់បង្កាន់ដៃបង់ប្រាក់ច្រើនសន្លឹកក៏ដោយ។ អ្នកប្រមូលចំណូល ត្រូវរក្សាទុកសៀវភៅបង្កាន់ដៃបង់ប្រាក់ដែលបានប្រើប្រាស់ខ្លះហើយនោះ សម្រាប់ការត្រួតពិនិត្យ និងជម្រះបញ្ជី។

ក្នុងករណីចាំបាច់ដែលមានតម្រូវការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រភេទផ្សេង ក្រៅពីបង្កាន់ដៃបង់ប្រាក់ទាំងពីរប្រភេទខាងលើនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងមានគោលការណ៍ណែនាំដោយឡែក។

## ផ្នែកទី២
## សមត្ថកិច្ច និងការទទួលខុសត្រូវ

### ៥- ការបោះពុម្ពបង្កាន់ដៃបង់ប្រាក់

នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តទៅនេះសរសេរកាត់ថា នា.ចមព) ត្រូវកំណត់អំពីទម្រង់ លក្ខណបច្ចេកទេស និងបរិមាណនៃបង្កាន់ដៃបង់ប្រាក់ និងធ្វើកិច្ចសហការជាមួយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការបោះពុម្ពបង្កាន់ដៃបង់ប្រាក់ តាមនីតិវិធីហិរញ្ញវត្ថុ។

ជារៀងរាល់ឆ្នាំនា.ចមព ត្រូវរៀបចំកម្មវិធីប្រជុំពិភាក្សាជាមួយនឹងអង្គភាពពាក់ព័ន្ធ ដើម្បីសិក្សានូវបរិមាណប្រើប្រាស់ និងគុណភាពបង្កាន់ដៃបង់ប្រាក់ ស្របតាមតម្រូវការ។ ទន្ទឹមនឹងនេះ នា.ចមព ត្រូវរៀបចំគម្រោងចំណាយថវិកាប្រចាំឆ្នាំ សម្រាប់ការបោះពុម្ពបង្កាន់ដៃទាំងនេះ ផ្ញើជូននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៦- ការស្នើសុំបង្កាន់ដៃបង់ប្រាក់

ការស្នើសុំបង្កាន់ដៃបង់ប្រាក់ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

៦.១- ក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីតម្រូវការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នៅរដ្ឋបាលកណ្តាល ដោយភ្ជាប់មកជាមួយនូវស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៣.១ សហវ/ចមព ព្រមទាំងបញ្ជីតាមដានការប្រមូលចំណូលតាមរយៈបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៤.១ សហវ/ចមព។

៦.២- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីតម្រូវការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នៅមន្ទីរជំនាញរាជធានី ខេត្ត និងសម្រាប់ការប្រើប្រាស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់មកជាមួយនូវស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៣.២ សហវ/ចមព ព្រមទាំងបញ្ជីតាមដានការប្រមូលចំណូលតាមរយៈបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៤.២ សហវ/ចមព។

**៧- ការបើកផ្តល់បង្កាន់ដៃបង់ប្រាក់**

បង្កាន់ដៃបង់ប្រាក់ទាំងពីរប្រភេទ ស្ថិតក្រោមការគ្រប់គ្រង និងបើកផ្តល់ដោយនា.ចមព។ នា.ចមព ត្រូវទទួលខុសត្រូវក្នុងការបើកផ្តល់បង្កាន់ដៃបង់ប្រាក់ឱ្យបានរួសរាន់ទាន់ពេលវេលា តាមការស្នើសុំរបស់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

**៨- ការប្រមូល និងការបង់ចំណូល**

អ្នកប្រមូលចំណូលនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រមូលចំណូលប្រកបដោយស្មារតីទទួលខុសត្រូវ និងត្រូវបង់ចំណូលដែលប្រមូលបានចូលរតនាគារ ឬធនាគារ តាមការណែនាំរបស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ផ្នែកទី៣
## ការកត់ត្រាតាមដាន និងផ្ទៀងផ្ទាត់សន្និធិបង្កាន់ដៃបង់ប្រាក់

**៩- ការកត់ត្រាតាមដានស្ថានភាពបង្កាន់ដៃបង់ប្រាក់**

ការគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់រដ្ឋលេខាធិការចំណូល និងនា.ចមព ដែលត្រូវយកចិត្តទុកដាក់កត់ត្រាតាមដានឱ្យបានច្បាស់លាស់។ ការកត់ត្រាអំពីការគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ត្រូវប្រមូលផ្តុំនៅរដ្ឋលេខាធិការចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់។

**៩.១- ការកត់ត្រាតាមដាននៅក្រសួង ស្ថាប័ន**

រដ្ឋលេខាធិការចំណូលត្រូវកត់ត្រាស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៣.១ សហវ/ចមព សម្រាប់តាមដានការបញ្ចូលបង្កាន់ដៃបង់ប្រាក់ពីការបើកផ្តល់ដោយនា.ចមព និងការបញ្ចេញបង្កាន់ដៃបង់ប្រាក់សម្រាប់អ្នកប្រមូលចំណូល បើកផ្តល់បន្ត ឬប្រើប្រាស់។

**៩.២- ការកត់ត្រាតាមដាននៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

រដ្ឋលេខាធិការចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ ត្រូវកត់ត្រាស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៣.២ សហវ/ចមព សម្រាប់តាមដានការបញ្ចូលបង្កាន់ដៃបង់ប្រាក់ពីការបើកផ្តល់ដោយនា.ចមព និងការបញ្ចេញបង្កាន់ដៃបង់ប្រាក់សម្រាប់អ្នកប្រមូលចំណូល បើកផ្តល់បន្ត ឬប្រើប្រាស់។

**៩.៣- ការកត់ត្រាតាមដាននៅនា.ចមព**

នា.ចមព ត្រូវកត់ត្រាតាមដានសន្និធិបង្កាន់ដៃបង់ប្រាក់ដូចមានគំរូស្តីពីស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់។ គំរូស្តីពីស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់នេះ ត្រូវចែកចេញជាពីរផ្នែករួមមាន :

- ផ្នែកទី១ ជាការកត់ត្រាស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៣.៣ សហវ/ចមព សម្រាប់តាមដានការបញ្ចូលបង្កាន់ដៃបង់ប្រាក់ពីការបោះពុម្ព និងការបញ្ចេញបង្កាន់ដៃបង់ប្រាក់ផ្តល់ជូនក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល នៃរដ្ឋបាលកណ្តាល សម្រាប់បើកផ្តល់បន្ត ឬប្រើប្រាស់។
- ផ្នែកទី២ ជាការកត់ត្រាស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ ០៣.៤ សហវ/ចមព សម្រាប់តាមដានការបញ្ចូលបង្កាន់ដៃបង់ប្រាក់ពីការបោះពុម្ព និងការបញ្ចេញបង្កាន់ដៃបង់ប្រាក់ផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត សម្រាប់បើកផ្តល់បន្ត ឬប្រើប្រាស់។

**១០- ការកត់ត្រាតាមដានចំណូលពីបង្កាន់ដៃបង់ប្រាក់**

ចំណូលពីការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ គឺជាចំណូលជាសាច់ប្រាក់ដែលត្រូវមានការកត់ត្រាឱ្យបានច្បាស់លាស់ក្នុងបញ្ជីតាមដានការប្រមូលចំណូលតាមរយៈបង្កាន់ដៃបង់ប្រាក់ ។

**១០.១- ការកត់ត្រាតាមដាននៅក្រសួង ស្ថាប័ន**

រដ្ឋទេយ្យករចំណូល ត្រូវកត់ត្រាក្នុងបញ្ជីតាមដានការប្រមូលចំណូលតាមរយៈបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ០៤.១ សហវ/ចមព សម្រាប់តាមដានអំពីការប្រមូលចំណូល និងការបង់ចំណូលប្រចាំខែ របស់អ្នកប្រមូលចំណូលដែលអនុវត្ត នៅក្រោមក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល នៃរដ្ឋបាលកណ្តាល។

**១០.២- ការកត់ត្រាតាមដាននៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

រដ្ឋទេយ្យករចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវកត់ត្រាក្នុងបញ្ជីតាមដានការប្រមូលចំណូលតាមរយៈបង្កាន់ដៃបង់ប្រាក់ តាមគំរូលេខ០៤.២ សហវ/ចមព សម្រាប់តាមដានអំពីការប្រមូលចំណូល និងការបង់ចំណូលប្រចាំខែ របស់អ្នកប្រមូលចំណូលដែលអនុវត្ត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងនៅមន្ទីរជំនាញរាជធានី ខេត្ត ដែលជាខ្សែបណ្តោយរបស់រដ្ឋបាលថ្នាក់ជាតិ។

**១១- របបរបាយការណ៍**

នៅរៀងរាល់ដំណាច់ខែនីមួយៗ រដ្ឋទេយ្យករចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ ត្រូវធ្វើរបាយការណ៍អំពីស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ និងចំណូលទទួលបានពីការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ទាំងពីរប្រភេទ ដូចខាងក្រោម :

- ចំពោះក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល នៃរដ្ឋបាលកណ្តាល ត្រូវធ្វើរបាយការណ៍យ៉ាងហោចណាស់ចំនួនពីរច្បាប់ ដាក់ជូនអាណាប័កពិនិត្យ និងចុះហត្ថលេខា រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នា.ចមព)មួយច្បាប់ ឱ្យបានមុនថ្ងៃទី០៧ នៃខែបន្ទាប់ និងមួយច្បាប់ទៀត ត្រូវរក្សាទុកភ្ជាប់នឹងសំណុំរឿងសម្រាប់ការត្រួតពិនិត្យ។
- ចំពោះមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍យ៉ាងហោចណាស់ចំនួនបីច្បាប់ ដាក់ជូនប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងចុះហត្ថលេខា រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(នា.ចមព) មួយច្បាប់ ផ្ញើជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មួយច្បាប់ ឱ្យបានមុនថ្ងៃទី២០ នៃខែបន្ទាប់ និងមួយច្បាប់ទៀត ត្រូវរក្សាទុកភ្ជាប់នឹងសំណុំរឿងសម្រាប់ការត្រួតពិនិត្យ។

ផ្អែកតាមរបាយការណ៍ដែលទទួលបានពីរដ្ឋទេយ្យករចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ នា.ចមពត្រូវធ្វើការបូកសរុបរបាយការណ៍ទាំងពីរប្រភេទប្រចាំត្រីមាស ដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជ្រាបអំពីស្ថានភាពដាក់ឱ្យអនុវត្តការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នេះ។

នា.ចមពត្រូវសហការណ៍ឱ្យបានទៀងទាត់ជាមួយរដ្ឋទេយ្យករចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ ដើម្បីណែនាំដល់អ្នកប្រមូលចំណូលក្នុងការកត់ត្រាស្ថានភាពបញ្ចូល បញ្ចេញបង្កាន់ដៃបង់ប្រាក់ និងកត់ត្រាក្នុងបញ្ជីតាមដានការប្រមូលចំណូលតាមរយៈបង្កាន់ដៃបង់ប្រាក់ឱ្យបានជាប្រចាំ ដើម្បីអ្នកប្រមូលចំណូលមានលទ្ធភាពរៀបចំ និងផ្តល់របាយការណ៍ឱ្យបានទាន់ពេលវេលា។

**១២- ការផ្ទៀងផ្ទាត់សន្និធិបង្កាន់ដៃបង់ប្រាក់**

រៀងរាល់ដំណាច់ឆ្នាំ នា.ចមព ត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិបង្កាន់ដៃបង់ប្រាក់ដែលបានបើកផ្តល់ជាមួយនឹងរដ្ឋទេយ្យករចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ ព្រមទាំងធ្វើការជម្រះបញ្ជីបង្កាន់ដៃបង់ប្រាក់ដែលនៅសល់។ កំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់សន្និធិបង្កាន់ដៃបង់ប្រាក់នេះ ត្រូវមានការចុះហត្ថលេខាដោយមន្ត្រីនា.ចមព ដែលត្រូវបានចាត់បញ្ជូនឱ្យធ្វើការផ្ទៀងផ្ទាត់ និងរដ្ឋទេយ្យករចំណូល ឬមន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រងសន្និធិបង្កាន់ដៃបង់ប្រាក់ ព្រមទាំងមានការឯកភាពពីប្រធានអង្គភាពនីមួយៗផង។

សេចក្តីដែលបានណែនាំខាងលើនេះ ប្រសិនបើមានចំណុចណាមួយមានភាពមិនច្បាស់លាស់ ឬក្នុងការអនុវត្តជួបប្រទះបញ្ហាផ្សេងៗ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ដើម្បីធ្វើការបកស្រាយបញ្ជាក់បន្ថែម និងចាត់វិធានការដោះស្រាយឱ្យបានសមស្របទៅតាមនីតិវិធីនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានក្តីសង្ឃឹមលើស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរ និងអង្គភាព នៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការយកចិត្តទុកដាក់អនុវត្តសារាចរណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែងប្រមូលចំណូលមិនមែនសារពើពន្ធ ដើម្បីកៀរគរប្រាក់ចំណូលចូលថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

*<u>ចម្លងជូន</u> :*

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អាជ្ញាធរសវនកម្មជាតិ*
- *គ្រប់ក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល*
- *រដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត*
- *គ្រប់អគ្គនាយកដ្ឋាន និងនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត*
- *រតនាគាររាជធានី ខេត្ត*
- *ឯកសារ - កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ១២៤២៩ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១០

# **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

## **ជំរាបមក**

លោក YU, JUN-CHIEH ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ខេអ៊ី ឃ្យូធី (ខេមបូឌា)**
អាសយដ្ឋាន : លេខ L ៨ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កម្មវត្ថុ** : ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ខេអ៊ី ឃ្យូធី (ខេមបូឌា)** KE QT ( CAMBODIA ) Co., Ltd.

**យោង** : - សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី 25 / 05 / 2010
- កំណត់ហេតុនៃអង្គប្រជុំនិងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី 20 / 05 / 2010
- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ថ្ងៃទី 20 / 05 / 2010
- សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ 415 ចេញផ្សាយថ្ងៃទី 15 - 06 - 2010

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ខេអ៊ី ឃ្យូធី (ខេមបូឌា)** KE QT ( CAMBODIA ) Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13703/ 09P ចុះថ្ងៃទី 25 - 03 - 2009 ទៅតាមចំណុចដូចមានក្នុងលិខិតស្នើ និងយោងខាងលើគឺ :

-ការប្តូរទីស្នាក់ការក្រុមហ៊ុន :
-ទីស្នាក់ការចាស់ : លេខ P ១៥ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។
ប្តូរមកទីស្នាក់ការថ្មី : លេខ L ៨ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-ការលាលែងចេញសមាជិកហ៊ុន ចំនួន ០១ រូប គឺលោកស្រី **ហែម ស៊ីនួន** " អភិបាលចាស់ "

-ការបញ្ចូលសមាជិកហ៊ុនថ្មី ចំនួន ០៣ រូប គឺលោក YU, JUN-CHIEH លោក HSIEH, TING-WANG និងលោកស្រី **ហែម ណារី**

-ការធ្វើអនុប្បទានភាគហ៊ុន

-សមាសភាពសមាជិកភាគហ៊ុនថ្មី :
- លោក YU, JUN-CHIEH (សញ្ជាតិ : ចិន ) កាន់កាប់ភាគហ៊ុនចំនួន ៤០០ ភាគហ៊ុន
- លោក HSIEH, TING-WANG ( សញ្ជាតិ : ចិន ) កាន់កាប់ភាគហ៊ុនចំនួន ៣០០ ភាគហ៊ុន
- លោកស្រី **ហែម ណារី** ( សញ្ជាតិ : ខ្មែរ ) កាន់កាប់ភាគហ៊ុនចំនួន ៣០០ ភាគហ៊ុន

-សមាសភាពក្រុមប្រឹក្សាភិបាលថ្មី :

- លោក YU, JUN-CHIEH ប្រធានក្រុមប្រឹក្សាភិបាល
- លោក HSIEH, TING-WANG អភិបាល
- លោកស្រី **ហែម ណារុំ** អភិបាល

-ការលុបកម្មវត្ថុអាជីវកម្ម : -ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង ។

-ការប្តូរទ្រង់ទ្រាយក្រុមហ៊ុនពីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត មកជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

-ការប្តូរសញ្ជាតិក្រុមហ៊ុន :

ពីសញ្ជាតិ : ខ្មែរ

មកសញ្ជាតិ : បរទេស

និងប្តូរអត្តលេខចុះបញ្ជីពាណិជ្ជកម្មពីលេខ Co. 13703/ 09P ចុះថ្ងៃទី 25 - 03 - 2009 ទៅលេខ Co. 13703E/2009 ចុះថ្ងៃទី 25 - 05 - 2010 ឯវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ២៦៥៥ ពណ.ចបព ចុះថ្ងៃទី ០១- ០៧ - ២០០៩ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តតាមការសមស្រប ។/.

**ទេសរដ្ឋមន្ត្រី**

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ហូ សារ៉ាន់**

**ចម្លងជូន:**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល - ធនាគារជាតិនៃកម្ពុជា
- ក្រសួងទេសចរណ៍ - ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ ✓
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៥៩៣៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **អ.អ.ហ្សេត. គ្លូប៊ល ត្រេដ អេជេនស៊ី**
R.R.Z. GLOBAL TRADE AGENCY Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១០៦៨E/២០១០ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :

| | | |
|---|---|---|
| លោក | ZAKARIA BIN YAAKOB | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក | RAZALI BIN KASSIM | អភិបាល |
| លោក | MAT RAHIM BIN ALI | អភិបាល |
| លោក | AHMAD KECIL BIN KASSIM | អភិបាល |

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៣ EoE1 ផ្លូវជាតិលេខ ៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការដូសដុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនិមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
អនុរដ្ឋលេខាធិការ

ហ៊ុ_សាភីន់

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ឃ.ល.រ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៩៦៣៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **អង្គរ មានជ័យ (ខេមបូឌា) លីមីធីត**
ANGKOR MEANCHEY (CAMBODIA) LIMITED

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១០៨៦KH/២០១០ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
លោក **គីម សុខហេង** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ជា ថាវី** អភិបាល
លោក **ជា រតនា** អភិបាល
លោក **គីម សុខសម្បត្តិ** អភិបាល
លោកស្រី **គីម សុខឡេង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ P ០៧ ផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូលនិងផ្គត់ផ្គង់ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្គូសផ្គុំសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងបំពេញបែបបទទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ហ៊ូ-សារ៉េន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.សរ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៥៥៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **គុន្ន រីខុន ហូលឌីង**
KUNN REKON HOLDINGS Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១០៨១KH/២០១០ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក YAU CHENG MING ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី CHEN AH PHENG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២៩ ផ្លូវលេខ ២០០ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួលដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- បេរវេលា ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកលប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

ហុ សារ៉ាន់

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ** [illegible] **ពណ.ចបព**

ភ្នំពេញថ្ងៃទី ០៣ ខែ [illegible] ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**សូមបញ្ជាក់ថា :**

លោក **ឈិន ណារិទ្ធ** អភិបាលក្រុមហ៊ុន **នីកូ អេឡិកទ្រិក**
អាសយដ្ឋាន : លេខ ៦៨ ផ្លូវលេខ ៤៥៦ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កម្មវត្ថុ** : ការស្នើសុំប្តូរទម្រង់ទ្រព្យសហគ្រាសឯកបុគ្គល មកជា សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។

**យោង** : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៧-០៥-២០១០
-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ចុះថ្ងៃទី ២៧-០៥-២០១០
-សេចក្តីប្រកាសស្តីពីការបង្កើតក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្ម លេខ ៤១៦ ចេញផ្សាយថ្ងៃទី ៣០-០៦-២០១០

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែសហគ្រាសឯកបុគ្គល **នីកូ អេឡិកទ្រិក** NECO ELECTRIC ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ So. ០១០៣KH/២០១០ ចុះថ្ងៃទី ០៣-០៣-២០១០ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **នីកូ អេឡិកទ្រិក**
**NECO ELECTRIC Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១០៦៤KH/២០១០** ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០
មានទម្រង់ទ្រព្យជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោក **ឈិន ណារិទ្ធ**
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦៨ ផ្លូវលេខ ៤៥៦ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ ពិសេសទិញ លក់ និងផ្គត់ផ្គង់ សំភារៈ បរិក្ខារអគ្គិសនីគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែករដ្ឋបាលពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ឯលិខិតគោលការណ៍លេខ ១១៩៥ ពណ.ចបព ចុះថ្ងៃទី ១០-០៣-២០១០ និងវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ១១៩៥ ពណ.ចបព ចុះថ្ងៃទី ១០-០៣-២០១០ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។ លោក **ឈិន ណារិទ្ធ** ត្រូវទទួលខុសត្រូវរាល់បំណុលទាំងឡាយរបស់សហគ្រាសឯកបុគ្គល ដែលកើតមានមុនការកែប្រែនេះ ។

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អនុរដ្ឋលេខាធិការ**

**ហ៊ុ-សារ៉ន់**

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស : - ឯកសារ -កាលប្បវត្តិ